# លិខិតចំហ៖ អ្នកសារព័ត៌មានអំពាវនាវឱ្យរដ្ឋាភិបាលបំភ្លឺសេចក្តីណែនាំចុងក្រោយដល់សារព័ត៌មាន

ជូនចំពោះ៖
**ឯកឧត្តម ខៀវ កាញារីទ្ធ** រដ្ឋមន្រ្តីក្រសួងព័ត៌មាន

ថ្ងៃទី ៥ ខែកុម្ភៈ ឆ្នាំ ២០២១

ឯកឧត្តមជាទីគោរព!

យើងខ្ញុំជាអង្គការ សមាគមធ្វើការផ្នែកវិស័យសារព័ត៌មានដែលរួមមានមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM) សម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (CamboJA) សហព័ន្ធអ្នកសារព័ត៌អន្តរជាតិ (IFJ) និងក្លឹបអ្នកសារព័ត៌មានបរទេសនៃកម្ពុជា (OPCC) សម្តែងនូវការព្រួយបារម្ភយ៉ាងខ្លាំងចំពោះបទបញ្ជាចុងក្រោយដែលរារាំងអ្នកសារព័ត៌មានមិនឱ្យយកព័ត៌មានអំពី "ការស៊ើបអង្កេតរបស់ប៉ូលីស" ដែលអាចរឹតត្បិតសិទ្ធិសេរីភាពអ្នកសារព័ត៌មានក្នុងការយកព័ត៌មាននៅក្នុងប្រទេសកម្ពុជា។

ស្នងការនគរបាលរាជធានីភ្នំពេញលោកស ថេត បានប្រកាសបទបញ្ជាថ្មីដល់មន្រ្តីនៅថ្ងៃទី២១ ខែមករា ដោយបានផ្សាយតាមបណ្តាញសង្គមហ្វេសប៊ុកថា អ្នកសារព័ត៌មានត្រូវតែហាមឃាត់មិនអោយថតជាវីដេអូ និងផ្សាយបន្តផ្ទាល់ការស៊ើបអង្កេតរបស់ប៉ូលីសអំពីសកម្មភាពឧក្រិដ្ឋ ក៏ដូចជាការកំណត់អត្តសញ្ញាណជនសង្ស័យ ឬទីតាំងរបស់ពួកគេ និងការបំពេញមុខងារផ្សេងទៀតរបស់មន្រ្តីប៉ូលីស។
បទបញ្ជានោះបន្ថែមថា ចំពោះអ្នកដែលរំលោភសេចក្តីណែនាំនេះនឹងត្រូវប្រឈមនឹងផ្លូវច្បាប់។

បីថ្ងៃមុនសេចក្តីណែនាំនេះត្រូវបានប្រកាស លោក ខៀវ កាញារីទ្ធ រដ្ឋមន្រ្តីក្រសួងព័ត៌មាន បានក្រើនរំលឹកដល់អ្នកសារព័ត៌មានទាំងអស់ចំពោះការថតរូបនិងយកព័ត៌មានទាក់ទងនឹងសកម្មភាពរបស់អាជ្ញាធរនៅក្នុងតំបន់ហាមឃាត់ ដោយអះអាងថាសមត្ថកិច្ចមានសិទ្ធិចាប់ខ្លួនអ្នកកាសែតពេលនោះតែម្តង។

អត្ថន័យនៃសេចក្តីណែនាំនេះនៅតែមិនច្បាស់និងទូលំទូលាយដែលអាចនាំឱ្យមានការរឹតត្បិតសេរីភាពនៃការបោះពុម្ពផ្សាយរបស់អ្នកសារព័ត៌មានដែលត្រូវបានការពារក្នុងមាត្រា ៤១ នៃរដ្ឋធម្មនុញ្ញនិងច្បាប់សារព័ត៌មានឆ្នាំ១៩៩៥ ។ ដូច្នេះ យើងជាអង្គការនិងសមាគមសារព័ត៌មាន បន្ទាប់ពីទទួលបានសំណើពីអ្នកសារព័ត៌មានជាសមាជិករបស់ពួកយើង សូមអំពាវនាវដល់រដ្ឋាភិបាលមេត្តាពន្យល់និងបញ្ជាក់អំពី សេចក្តីណែនាំនេះឱ្យបានច្បាស់ ដើម្បីធានាថាសិទ្ធិនិងសេរីភាពរបស់អ្នកសារព័ត៌មានដែលត្រូវបានធានាទាំងនៅក្នុងរដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជានិងច្បាប់អន្តរជាតិ មិនត្រូវបានរិតត្បិត។

នៅក្នុងប៉ុន្មានខែថ្មីៗនេះ អ្នកកាសែតជាច្រើនបានទទួលរងនូវការឃាយឃីនិងត្រូវបានអាជ្ញាធរប្រាប់ អោយបញ្ឈប់ការថតរូបថតនិងផ្សាយបន្តផ្ទាល់ក្នុងពេលតវ៉ានិងព្រឹត្តិការណ៍ដទៃទៀតដែលប៉ូលីសកំពុងបំពេញភារកិច្ច។ អង្គការសមាគមដែលបានចុះហត្ថលេខាខាងលើ បានរកឃើញថាយ៉ាងហោចណាស់មានករណីមួយ នៅចុងខែមករាដែលសមត្ថកិច្ចបានកោះហៅអ្នកសារព័ត៌មានមកអប់រំនិងណែនាំអំពីការហាមឃាត់មិនឱ្យថតនិងផ្សាយបន្តផ្ទាល់ ដោយបានដកស្រង់និងយោងតាមប្រសាសន៍របស់រដ្ឋមន្ត្រីក្រសួងព័ត៌មាន។

យើងលើកទឹកចិត្តឱ្យអ្នកសារព័ត៌មានទាំងអស់ប្រកាន់ខ្ជាប់វិជ្ជាជីវៈសារព័ត៌មាន និងគោរពក្រមសីលធម៌ ។

យើងសូមអំពាវនាវឱ្យរដ្ឋាភិបាលពន្យល់ឱ្យបានច្បាស់នូវបទបញ្ជាណែនាំចុងក្រោយនេះ ហើយលប់បំបាត់ចោលនូវរាល់បទបញ្ជា ច្បាប់ និងសេចក្តីណែនាំដែលមិនមានភាពចាំបាច់ទាំងអស់ ដែលបង្កការរារាំងដល់ការងាររបស់អ្នកសារព័ត៌មាន និងដើម្បីធានាបានថាអ្នកសារព័ត៌មានទាំងអស់អាចអនុវត្តនូវសិទ្ធិរបស់ខ្លួនក្នុងការរាយការណ៍ព័ត៌មានដោយសេរី និងគ្មានការភ័យខ្លាច។

ដោយភាពស្មោះត្រង់ពីយើងខ្ញុំ

អង្គការសមាគមន៍ដែលបានចុះហត្ថលេខា

១. មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM)
២. សម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (CamboJA)
៣. សហព័ន្ធអ្នកសារព័ត៌អន្តរជាតិ (IFJ)
៤. ក្លឹបអ្នកសារព័ត៌មានបរទេសនៃកម្ពុជា (OPCC)

ចម្លងជូន៖

**សម្តេចក្រឡាហោមស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ